# សេចក្តីប្រកាសរួមរបស់ភ្នាក់ងារអង្គការសហប្រជាជាតិ
# ស្តីពី
# មជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ

**ភ្នាក់ងារអង្គការសហប្រជាជាតិ ស្នើសុំឱ្យរដ្ឋទាំងឡាយបិទមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ ហើយអនុវត្តន៍ការផ្តល់សេវាសុខភាព និងសេវាសង្គមដែលមានលក្ខណៈស្ម័គ្រចិត្ត ផ្អែកលើភស្តុតាង និងសិទ្ធិមនុស្សជាមូលដ្ឋាន នៅតាមសហគមន៍ ។**

ការបន្តរក្សាមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ ដែលនៅទីនោះ អ្នកដែលគេសង្ស័យថា ជាអ្នកប្រើគ្រឿងញៀន អ្នកញៀនគ្រឿងញៀន អ្នកពាក់ព័ន្ធនឹងបញ្ហារកស៊ីផ្លូវភេទ កុមារដែលជាជនរងគ្រោះដោយអាជីវកម្មផ្លូវភេទ ត្រូវបានគេឃុំឃាំងដោយមិនអនុវត្តន៍តាមនីតិវិធីច្បាប់ ស្ថិតក្រោមឈ្មោះថា **ការព្យាបាល ឬ ការស្តារនីតិសម្បទា** គឺជាការព្រួយបារម្ភយ៉ាងខ្លាំង ។

មជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ បង្កើតឱ្យមានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងគំរាមកំហែងដល់សុខភាពជនជាប់ឃុំទាំងនោះ ដោយរាប់បញ្ចូលទាំងភាពងាយរងគ្រោះទៅនឹងការចម្លងរោគអេដស៍ និងរោគរបេងផងដែរ ។ លក្ខណ្ឌសម្រាប់ការឃុំឃាំងនៅក្នុងមឃ្ឈមណ្ឌលទាំងនេះ មានការប្រែប្រួលពីមជ្ឈមណ្ឌលមួយទៅមជ្ឈមណ្ឌលមួយ និងពីប្រទេសមួយទៅប្រទេសមួយទៀត ។ ប៉ុន្តែ ការឃុំឃាំងរបៀបនេះតែងតែកើតឡើងដោយមិនអនុវត្តន៍ឱ្យគ្រប់ជ្រុងជ្រោយទៅតាមនីតិវិធីនៃច្បាប់ មិនឆ្លងកាត់ការកាត់ក្តីពីតុលាកា ឬពុំអនុញ្ញាតឱ្យមានមេធាវីការពារក្តីឡើយ ។ ការដកសិទ្ធិសេរីភាពដោយមិនអនុវត្តន៍ទៅតាមនីតិវិធីច្បាប់ គឺជាការរំលោភបំពានដែលមិនអាចទទួលយកបានមួយចំពោះស្តង់ដាសិទ្ធិមនុស្សដែលបានទទួលស្គាល់ជាអន្តរជាតិ ។ លើសពីនេះទៅទៀត ការឃុំឃាំងនៅក្នុងមជ្ឈមណ្ឌលទាំងនេះត្រូវបានគេរាយការណ៍ថា បានរំលោភបំពានទាំងផ្លូវកាយ និងផ្លូវភេទ បង្ខំឱ្យធ្វើការងារធ្ងន់ស្ថិតក្នុងលក្ខណ្ឌងាយរងគ្រោះ គ្មានការថែទាំសុខភាព និងវិធានការផ្សេងៗទៀតដែលរំលោភបំពានទៅនឹងសិទ្ធិមនុស្ស ។

ពុំមានភស្តុតាងណាមួយដែលបញ្ជាក់ថា មជ្ឈមណ្ឌលទាំងនេះ គឺជាកន្លែងអំណោយផល ឬមានប្រសិទ្ធិភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀន សម្រាប់ការស្តារនីតិសម្បទាអ្នកពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទ ឬសម្រាប់កុមាររងគ្រោះដោយសារអាជីវកម្មផ្លូវភេទ ការរំលោភបំពាន ឬកុមារដែលខ្វះការថែទាំ និងការការពារនោះឡើយ ។

ភ្នាក់ងារអង្គការសហប្រជាជាតិទាំងអស់ដែលបានចុះហត្ថលេខាសេចក្តីប្រកាសរួមនេះ ស្នើសុំដល់រដ្ឋទាំងឡាយដែលដំណើរការមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ បិទមជ្ឈមណ្ឌលទាំងនោះដោយមិនពន្យាពេលវេលា ហើយដោះលែងអ្នកជាប់ឃុំឃាំងទាំងនោះឱ្យមានសេរីភាពឡើងវិញ ។ បន្ទាប់ពីការដោះលែង សេវាថែទាំសុខភាពសមស្របគួរត្រូវបានផ្តល់ជូនដល់អ្នកទាំងនោះទៅតាមសេចក្តីត្រូវការ ដោយផ្អែកទៅតាមគោលការណ៍ស្ម័គ្រចិត្ត នៅតាមសហគមន៍ ។ សេវាទាំងនេះ គួររាប់បញ្ចូលទាំងសេវាព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន សេវាបង្កា ព្យាបាលថែទាំ និងគាំទ្រ ជម្ងឺអេដស៍ និងជម្ងឺរបេង ក៏ដូចជាសេវាសុខភាព ច្បាប់ និងសេវាសង្គមផ្សេងៗទៀត ដើម្បីដោះស្រាយបញ្ហារំលោភបំពានផ្លូវកាយ និងផ្លូវភេទ ព្រមទាំងជួយសម្រួលដល់ការធ្វើសមាហរណកម្ម ។ ភ្នាក់ងារអង្គការសហប្រជាជាតិ ត្រៀមខ្លួនជាស្រេចក្នុងការបំពេញការងារជាមួយរដ្ឋនានានៅពេលចាប់ផ្តើមដំណើរការបិទមជ្ឈមណ្ឌលឃុំឃាំង និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ ហើយអនុវត្តន៍នូវជំរើសនានាដែលមានលក្ខណៈស្ម័គ្រចិត្ត គ្មានការឃុំឃាំង និងផ្អែកលើភស្តុតាងជាមូលដ្ឋាននៅតាមសហគមន៍ ។

ក្នុងករណីដែលរដ្ឋណាមួយពុំមានលទ្ធភាពក្នុងការបិទមជ្ឈមណ្ឌលទាំងនេះភ្លាមៗនោះ ដោយមិនបង្អង់ ភ្នាក់ងារអង្គការសហប្រជាជាតិទាំងអស់ ស្នើសុំដោយទទូចដល់រដ្ឋនោះឱ្យបង្កើតឱ្យបានឆាប់រហ័សនូវជំហានដូចខាងក្រោម៖

- ដំណើរការពិនិត្យឡើងវិញនូវការឃុំឃាំងក្នុងមជ្ឈមណ្ឌលនានា ដើម្បីធានាថា ពុំមានការឃុំឃាំងដោយអយុត្តិធម៌ ហើយការឃុំឃាំងនានាគឺធ្វើទៅតាមស្តង់ដាអន្តរជាតិនីតិវិធីនៃច្បាប់ និងផ្តល់ជាជំរើសនានាទៅនឹងការឃុំខ្លួននៅក្នុងពន្ធធនាគារ ។ ការពិនិត្យឡើងវិញនេះ អាចជួយសម្រួលក្នុងការកំណត់អ្នកដែលត្រូវដោះលែងជាបន្ទាន់ និងអ្នកដែលត្រូវបញ្ជូនទៅកាន់កម្មវិធីព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើភស្តុតាងជាមូលដ្ឋាននៅតាមសហគមន៍ ។
- ដំណើរការពិនិត្យឡើងវិញនូវលក្ខខណ្ឌនានានៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយបង្ខំ ជាមួយនឹងការគិតគូរដល់ការកែលំអរលក្ខខណ្ឌទាំងនោះឱ្យបានឆាប់រហ័ស ដើម្បីឆ្លើយតបទៅនឹងស្តង់ដាជាអន្តរជាតិដែលអនុវត្តនៅតាមមន្ទីរឃុំឃាំងនានា ដោយរួមទាំងការទទួលបាននូវសេវាថែទាំសុខភាព សេវាសង្គម និងសេវាអប់រំដែលមានគុណភាព និងផ្អែក

លើភស្តុតាងជាមូលដ្ឋាន និងលុបបំបាត់ចោលនូវការព្យាបាលដែលគ្មានមនុស្សធម៌ និងគ្មានការទទួលស្គាល់ និងការបង្ខំឱ្យធ្វើការងារជាទម្ងន់[៣] រហូតដល់មជ្ឈមណ្ឌលទាំងនោះ ត្រូវបានបិទ ។

- ផ្តល់សេវាថែទាំសុខភាពក្នុងដំណើរការបិទមជ្ឈមណ្ឌល ដោយរួមទាំងការផ្តល់សេវាព្យាបាលជម្ងឺអេដស៍ និងជម្ងឺកាមរោគ ជម្ងឺរបេង និងជម្ងឺឱកាសនិយមផ្សេងៗទៀត ព្រមទាំងសេវាសុខភាព និងផ្លូវច្បាប់នានា ដើម្បីឆ្លើយតបទៅនឹងការរំលោភបំពានលើផ្លូវកាយ និងផ្លូវភេទ ។
- ពិនិត្យ និងធ្វើរបាយការណ៍តាមផ្លូវច្បាប់ និងដោយឯករាជ្យទៅលើដំណើរការបិទមជ្ឈមណ្ឌល និង
- ផ្អាកការបញ្ជូនចូលមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទានូវអ្នកប្រើគ្រឿងញៀន អ្នកពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទ និងកុមារដែលរងគ្រោះដោយសារការធ្វើអាជីវកម្មផ្លូវភេទ ។

ភស្តុតាងបានបង្ហាញថា ការឆ្លើយតបដែលមានប្រសិទ្ធិភាពទៅនឹងបញ្ហានៃការញៀនគ្រឿងញៀន និងគ្រោះថ្នាក់ផ្នែកសុខភាពដែលពាក់ព័ន្ធនឹងគ្រឿងញៀន ដូចជាការចម្លងរោគអេដស៍ ទាមទារនូវការព្យាបាលអាការៈញៀន ក្នុងលក្ខណ្ឌសុខភាពតាមរយៈវិធីសាស្រ្តដែលផ្អែកលើភស្តុតាង និងសិទ្ធិជាមូលដ្ឋានដែលភាគច្រើនទាមទារឱ្យមានការបង្កើត ។ រាល់កិច្ចអន្តរាគមន៍ថែទាំសុខភាព ដោយរួមបញ្ចូលទាំងការព្យាបាល អាការៈញៀនគ្រឿងញៀន គួរធ្វើទៅតាមគោលការណ៍ស្ម័គ្រចិត្ត និងមានការឯកភាព លើកលែងតែករណីពិសេសដែលកំណត់បានច្បាស់ថា ស្របទៅតាមច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ដែលធានាថា ការផ្តល់សេវាបែបនេះមិនមែនជាកម្មវត្ថុនៃការរំលោភបំពានឡើយ។ ការឆ្លើយតបនានាទៅនឹងបញ្ហានៃការប្រើប្រាស់គ្រឿងញៀន និងគ្រោះថ្នាក់ផ្នែកសុខភាពពាក់ព័ន្ធនឹងគ្រឿងញៀន គួររួមបញ្ចូលការបង្ការ និងព្យាបាល ជម្ងឺអេដស៍ ជម្ងឺកាមរោគ និងរបេងសម្រាប់អ្នកប្រើគ្រឿងញៀនផងដែរ ។

នៅកន្លែងដែលអ្នករកស៊ីផ្លូវភេទទទួលបានផលប្រយោជន៍ពីផ្លូវច្បាប់ ការការពារពីភាពរើសអើង និងការរំលោភបំពាន ហើយទទួលបាននូវការបង្ការ ព្យាបាល ថែទាំ និងគាំទ្របញ្ហាជម្ងឺអេដស៍ អ្នកទាំងនោះរួមទាំងដៃគូរបស់ពួកគេ អាចកាត់បន្ថយបានគួរឱ្យកត់សម្គាល់នូវភាពងាយរងគ្រោះទៅនឹងជម្ងឺអេដស៍ និងជម្ងឺកាមរោគផ្សេងៗទៀត ។

ក្នុងករណីកុមារអាយុក្រោម ១៨ ឆ្នាំ វិធានការឆ្លើយតបដែលមានប្រសិទ្ធិភាព និងសមស្របជាងគេ គឺជាវិធានការទាំងឡាយដែលផ្អែកលើគ្រួសារជាមូលដ្ឋាន និងកសាងលើភាពខ្លាំងរបស់សហគមន៍។ វិធានការទាំងនេះគឺជាជំរើសទី១ សមស្របទៅតាមសិទ្ធិរបស់ពួកគេក្នុងការទទួលបានសេវាសុខមាលភាព ការការពារ ការថែទាំ និងយុត្តិធម៌ ។ កុមារដែលបាន ឬបាននឹងកំពុងពាក់ព័ន្ធរបបរកស៊ីផ្លូវភេទ គួរត្រូវបានចាត់ទុកជាកុមារដែលរួចផុតពីការធ្វើអាជីវកម្មផ្លូវភេទ ស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ (១៩៨៩) និងអនុសញ្ញា ILO Worst Forms of Child Labour ឆ្នាំ១៩៩៩ (No 182) តែមិនមែនជា ជនល្មើសដែល

ត្រូវតែផ្តន្ទាទោសនោះឡើយ ។ កុមារដែលញៀនគ្រឿងញៀនគួរទទួលបានផលប្រយោជន៍ ពីកម្មវិធីនានាដែលយកសិទ្ធិ និងភស្តុតាងជមូលដ្ឋាន ដើម្បីជួយសម្រួលដំណើរជាសះស្បើយនិងការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍វិញ ។

រដ្ឋនានាបង្កើនការទទួលស្គាល់អំពីសេចក្តីព្រួយបារម្ភពាក់ព័ន្ធនឹងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាទាំងនេះ ដោយរួមទាំងកង្វះខាតប្រសិទ្ធិភាពក្នុងការបង្ការការលាប់ឡើងវិញ ការចំណាយខ្ពស់ និងផលប៉ះពាល់ជាអវិជ្ជមានទៅលើកិច្ចខិតខំប្រឹងប្រែងនានា ដើម្បីធានាការទទួលបានជាសកលសេវាបង្កាព្យាបាល ថែទាំ និងគាំទ្រជម្ងឺអេដស៍ ។ យើងកត់សម្គាល់ជាមួយនឹងការកោតសរសើរ ចំពោះប្រទេសមួយចំនួនដែលកំពុងដំណើរការកាត់បន្ថយចំនួនមណ្ឌលបែបនេះ ហើយពង្រឹងសមត្ថភាពថែមទៀតសម្រាប់វិធានការដែលមានលក្ខណៈស្ម័គ្រចិត្ត ផ្អែកលើភស្តុតាង និងសហគមន៍ជាមូលដ្ឋាន ។ ជំហានជាវិជ្ជមានទាំងនេះ គឺពិតជាមានសារៈសំខាន់ក្នុងការពង្រីកការយល់ដឹង និងគាំទ្រចំពោះវិធានការដោះស្រាយបញ្ហាញៀនគ្រឿងញៀន បញ្ហារកស៊ីផ្លូវភេទស និងបញ្ហានៃការធ្វើអាជីវកម្មផ្លូវភេទកុមារ ដែលផ្អែកលើភស្តុតាងផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រដែលមានស្រាប់ជាមូលដ្ឋាន ធានាការការពារសិទ្ធិមនុស្ស និងពង្រឹងផ្នែកសុខភាពសាធារណៈ ។

យើងប្តេជ្ញាធ្វើការងារជាមួយបណ្តាប្រទេសនានា ដើម្បីស្វែងរកជំរើសផ្សេងៗ ដើម្បីជំនួសមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទា ដោយរួមបញ្ចូលទាំងតាមរយៈការផ្តល់ការគាំទ្រផ្នែកបច្ចេកទេស ការកសាងសមត្ថភាព និងការស្វែងរកការគាំទ្រ ។ ទម្រង់នៃការជួយគាំទ្រអាចរួមមានដូចខាងក្រោម៖

- ចែករំលែកព័ត៌មាន និងបទពិសោធន៍ស្តីពីកម្មវិធីនានាដែលមានលក្ខណៈស្ម័គ្រចិត្ត ផ្អែកលើភស្តុតាង សហគមន៍ និងសិទ្ធិជាមូលដ្ឋាន សម្រាប់អ្នកញៀនគ្រឿងញៀន អ្នកពាក់ព័ន្ធនឹងការរកស៊ីផ្លូវភេទស និងកុមារដែលជាជនរងគ្រោះដោយអាជីវកម្មផ្លូវភេទ ។
- ធ្វើការពិភាក្សាជាមួយអ្នករៀបចំគោលនយោបាយ ដើម្បីបង្កើនការគាំទ្រកម្មវិធីនានាដែលមានលក្ខណៈស្ម័គ្រចិត្ត ផ្អែកលើភស្តុតាង សហគមន៍ និងសិទ្ធិជាមូលដ្ឋាន សម្រាប់អ្នកញៀនគ្រឿងញៀន ។
- កិច្ចសហប្រតិបត្តិការដែលមានលក្ខណៈពហុវិស័យក្នុងចំណោមស្ថាប័នអនុវត្តច្បាប់ សុខភាពយុត្តិធម៌ សិទ្ធិមនុស្ស សុខមាលភាពសង្គម និងស្ថាប័នត្រួតពិនិត្យគ្រឿងញៀន ដើម្បីជួយបង្កើតក្របខណ្ឌសកម្មភាពដើម្បីគាំទ្រដល់កម្មវិធីនានាដែលមានលក្ខណៈស្ម័គ្រចិត្តផ្អែកលើភស្តុតាង សហគមន៍ និងសិទ្ធិជាមូលដ្ឋាន សម្រាប់អ្នកញៀនគ្រឿងញៀន អ្នកពាក់ព័ន្ធនឹងការ រកស៊ីផ្លូវភេទស និងកុមារដែលជាជនរងគ្រោះដោយអាជីវកម្មផ្លូវភេទ និង
- បង្កើតសេវាផ្សេងៗ ដើម្បីដោះស្រាយមូលហេតុដែលបណ្តាលឱ្យភាពងាយរងគ្រោះ (ឧ. ភាពក្រីក្រ សមភាពជែនឌ័រ និងកង្វះខាតរចនាសម្ព័ន្ធគាំទ្រពីគ្រួសារ និងសហគមន៍)